ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រឹត្តិបត្រស្ថិតិ
# សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# ប្រចាំត្រីមាសទី១ ឆ្នាំ២០១៩


អគ្គនាយកដ្ឋានគោលនយោបាយ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ខែឧសភា ឆ្នាំ២០១៩

## មាតិកា


I. សេចក្តីអធិប្បាយសង្ខេប ............ ១

II. ស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ............ ៤

១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ ............ ៤

២. សូចនាករតាមវិស័យ ............ ៥

២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ............ ៥

២.៣. អត្រាប្តូរប្រាក់ ............ ៦

២.៤. ហិរញ្ញវត្ថុសាធារណៈ ............ ៧

២.៥. ឥណទាន និងរូបិយវត្ថុ ............ ១០

២.៦. វិស័យពាណិជ្ជកម្ម ............ ១១

២.៧. ការវិនិយោគឯកជន ............ ១៤

២.៨. វិស័យទេសចរណ៍ ............ ១៥

២.៩. វិស័យសំណង់ ............ ១៦

៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ ............ ១៧

III. ឧបសម្ព័ន្ធ ............ ១៩

# សេចក្តីអធិប្បាយសង្ខេប

ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈកម្ពុជា ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ បានបន្តរឹងមាំ ក្នុងនោះ អតិផរណា និងអត្រាប្តូរប្រាក់រៀលធៀបរូបិយអន្តរជាតិ ប្រែប្រួលក្នុងរង្វង់ទាប ខណៈទុនបម្រុងរូបិយប័ណ្ណបរទេសសុទ្ធ និងទំហំពាណិជ្ជកម្ម ជាពិសេសការនាំចេញទៅទីផ្សារសហរដ្ឋអាមេរិក បានកំពុងកើនឡើងជាលំដាប់។ ស្ថានភាពចំណូលដោយមានការគាំទ្រពីប្រសិទ្ធភាព នៃការកៀរគរចំណូល និងតម្រូវការខ្ពស់នៃការនាំចូល បានបន្តភាពប្រសើរឡើង និងរក្សាបានលំនឹងអតិរេកចរន្ត។ ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធៀប ផសស ឈានដល់ ១០២,៨% ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ ។

**ទេសចរណ៍** [1]

អ្នកដំណើរមកដល់កម្ពុជា សរុបប្រមាណ ១,៨៧ លាននាក់ បានកើន ៩,៧% ធៀបឆ្នាំ២០១៨ ប៉ុន្តែនៅទាបជាងកំណើនធៀបឆ្នាំ២០១៧ ដែលមានអត្រា ១៣,៩%។ អ្នកដំណើរឈរលំដាប់ថ្នាក់លេខមួយ គឺអ្នកដំណើរចិន ដែលមានចំណែក ៣៦,៤% នៃអ្នកដំណើរសរុប និងឈរលេខពីរ គឺភ្ញៀវទេសចរវៀតណាម ប្រមាណ ១០%។ ការពង្រីកផលិតផលទេសចរណ៍ គឺជាការងារអាទិភាព សម្រាប់ការទាក់ទាញចំណាយ និងចំនួនថ្ងៃស្នាក់នៅរបស់អ្នកដំណើរ។

**សំណង់** [2]

នៅត្រីមាសទី១ ឆ្នាំ២០១៩ នេះ សំណើសុំសាងសង់សរុបទូទាំងប្រទេស កើនឡើង ១២,៥% គឺពី ៨៧៩ គម្រោង ទៅ ៩៨៩ គម្រោង។ តម្លៃគម្រោង កើនឡើងប្រមាណ ៣ ដង ពី ៥០៧ លានដុល្លារ ទៅ ១ ៦៧៨ លានដុល្លារ។ ជាការកត់សម្គាល់ សំណើសុំសាងសង់ មានការរីកលូតលាស់ខ្លាំងក្នុងប្រភេទសំណង់លំនៅដ្ឋាន, សំណង់វិនិយោគ និងឧស្សាហកម្ម ធៀបរយៈពេលដូចគ្នាឆ្នាំ២០១៨។ ទន្ទឹមនឹងកំណើនសំណើសុំសាងសង់ ការនាំចូលបរិក្ខារសម្ភារសំណង់ កើនឡើង ៩,៦% គឺពី ៧៨៧ ៥២៦ តោន ទៅ ៨៥៣ ៣៣៥ តោន (គិតរួមទាំងការនាំចូលជាបន្ទុករដ្ឋ)។ **ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុលើផ្នែកសំណង់ បានថមថយកំណើនពី ៣៧,៤% មកនៅ ១៨,៣%។**

**ស្ថានភាពហិរញ្ញវត្ថុសាធារណៈ** [3]

យោងតាមទិន្នន័យបឋមពីអគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ នេះ ការប្រមូលចំណូលចរន្តសរុបនៅរដ្ឋបាលថ្នាក់ជាតិ អនុវត្តបានចំនួន ៤ ៨៥៦ ប៊ីលានរៀល ក្នុងនោះ ចំណូលសារពើពន្ធ អនុវត្តបាន ៨៩% ចំណូលចរន្តសរុប។ ក្នុងន័យនេះ ចំណូល

---
[1] ប្រភពទិន្នន័យៈ ក្រសួងទេសចរណ៍

[2] ប្រភពទិន្នន័យៈ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

[3] ទិន្នន័យបណ្តោះអាសន្នពីអគ្គនាយកដ្ឋានរតនាគារជាតិ ដែលពុំទាន់បានកត់ត្រាទាំងស្រុង ឬបច្ចុប្បន្នភាពទិន្នន័យនៅត្រីមាសក្រោយៗ។

ចរន្តសរុបត្រឹមដំណាច់ត្រីមាសទី១ ឆ្នាំ២០១៩ អនុវត្តបាន ២៥% នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។

**អតិផរណា និង អត្រាប្តូរប្រាក់ [4]**

អតិផរណាក្នុងត្រីមាសទី១ ឆ្នាំ២០១៩ ស្ថិតនៅក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ពោលគឺជាមធ្យមក្នុងអត្រា ២,៤% ទាបជាងត្រីមាសដូចគ្នាឆ្នាំ២០១៨ ដោយសារកំណើនចំណាយទាបនៃក្រុមអាហារ-ភេសជ្ជៈមិនមានជាតិស្រវឹង ២,៣% និងការដឹកជញ្ជូន ៣,៧%។ រយៈពេលដូចគ្នានេះ អត្រាប្តូរប្រាក់មានស្ថិរភាពល្អ ពោលគឺជាមធ្យម ៤ ០០៦ រៀល/ដុល្លារអាមេរិក។

**ប្រតិបត្តិការរូបិយវត្ថុ និងឥណទាន [5]**

អត្រារូបិយវត្ថុទូទៅធៀបនឹង ផសស (ផ៉ាន់ស្មាន) បានឈានដល់ ៨៥,៧% ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ ដោយកើនពី ៧៦,១% ឆ្នាំ២០១៧។ ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានកើនពី ២២,៤% ទៅ ២៥,៧% ក្នុងនោះ ឥណទានផ្តល់ទៅគ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ (២១,១%), តម្រូវការផ្ទាល់ខ្លួន (៣៩,៩០%) និងឥណទានពី MFIs បានថមថយកំណើនពី ៣៦% មកនៅត្រឹម ៣០%។ ជាការកត់សម្គាល់ ទំហំឥណទានក្នុងវិស័យសំណង់ (*) បានថមថយកំណើនពី ៣៧,៤% មកនៅត្រឹម ១៨,៣%។

**ពាណិជ្ជកម្មក្រៅប្រទេស [6]**

ការនាំចូលមុខទំនិញគ្រប់មុខ (គិតរួមទាំងការនាំចូលជាបន្ទុករដ្ឋ) នៅត្រីមាសទី១ ឆ្នាំ២០១៩ មានទំហំ ១៨ ៣៨១ ប៊ីលានរៀល ក្នុងអត្រាកំណើន ១៦% ធៀបនឹងឆ្នាំមុន ដោយសារកំណើនខ្ពស់លើផលិតផលនាំចូលចម្បង ដូចជា៖ ប្រេងឥន្ធនៈ (៩៣,១%), បរិក្ខារសំណង់ (៥០,៩%) និងទោចក្រយានយន្ត (៤១,៥%)។

ការនាំចេញសរុបរបស់កម្ពុជា នៅត្រីមាសទី១ ឆ្នាំ២០១៩ មានទំហំ ១២ ៩៣៧ ប៊ីលានរៀល ក្នុងអត្រាកំណើន១៣,៣% ក្នុងនោះ ការនាំចេញផលិតផលកាត់ដេរ និងស្បែកជើង(១៧,៦%) និងផលិតផលឧស្សាហកម្មផ្សេងៗទៀត (៥,៧%)។ ប៉ុន្តែការនាំចេញកង់ បានថមថយកំណើនពី ៥% នៅឆ្នាំ២០១៨ មកនៅត្រឹម ០,៩% នៅឆ្នាំ២០១៨។ ការនាំចេញទៅទីផ្សារអាមេរិក មានស្ថានភាពប្រសើរខ្លាំងក្នុងទឹកប្រាក់ ៨៨៧ លានដុល្លារ ក្នុងអត្រាកំណើន ៣៥,៤%។

[4] ប្រភពទិន្នន័យ: វិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ និងធនាគារជាតិ នៃកម្ពុជា

[5] ប្រភពទិន្នន័យ: ធនាគារជាតិ នៃកម្ពុជា

(*) និយមន័យ៖ ការផ្តល់ឥណទាន ដោយធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សម្រាប់វិស័យសំណង់

[6] ប្រភពទិន្នន័យ: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទិន្នន័យនាំចេញ-នាំចូល នឹងមានការកែសម្រួល។

ផលិតផលនាំចេញទៅទីផ្សារអឺរ៉ុប (EU28) មានទំហំ ១ ០៩២ លានដុល្លារ ក្នុងអត្រាកំណើនទាបប្រមាណ ១,៤% បានកំពុងបន្ថយចំណែកទីផ្សារនាំចេញរបស់កម្ពុជាពី ៣៧,៨% មកនៅ ៣៣,៨% ក្នុងត្រីមាសទី១ រវាងឆ្នាំ២០១៨ និងឆ្នាំ២០១៩។

**ការវិនិយោគឯកជន [7]**

ការវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេសដែលអនុម័តដោយ CDC នៅត្រីមាសទី១ ឆ្នាំ២០១៩ មាន ៦៣ គម្រោង លើទុនវិនិយោគប្រមាណ ១ ៩៣៦ លានដុល្លារ ខ្ពស់ជាងរយៈពេលដូចគ្នាឆ្នាំ២០១៨ ដែលមាន ៣៦ គម្រោង និងទុនវិនិយោគ ប្រមាណ ៤៦៩ លានដុល្លារ ប៉ុណ្ណោះ។ នៅត្រីមាសទី១ ឆ្នាំ២០១៩ នេះ ការវិនិយោគប្រមាណ ៥៤,៣% គឺប្រើប្រាស់ទុនវិនិយោគក្នុងស្រុក។

ᨄᨄ❈ᨄᨄ

[7] ប្រភពទិន្នន័យៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# ស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ

*តារាង 1 ÷ ទិន្នន័យសេដ្ឋកិច្ចសំខាន់ៗ*

| | ឯកតា | ត្រីមាសទី១ | | |
|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ |
| **សូចនាករម៉ូលដ្ឋាន** | | | | |
| ផសស ថ្លៃបច្ចុប្បន្ន -- (ប៉ាន់ស្មានឆ្នាំ២០១៩) | ប៊ីលានរៀល | 89,754 | 98,786 | 108,590 |
| អតិផរណា (កំណើនមធ្យមប្រចាំឆ្នាំ) | % | 3.3% | 2.6% | 2.4% |
| អត្រាប្តូរប្រាក់រៀល/ ដុល្លារ (មធ្យមប្រចាំឆ្នាំ) | រៀល | 4,016 | 4,012 | 4,006 |
| **ឥណទាន និងរូបិយវត្ថុ** | | | | |
| កំណើនរូបិយវត្ថុទូទៅ | % នៃ ផសស | 18.8% | 24.1% | 23.8% |
| អត្រារូបិយវត្ថុទូទៅ | % នៃ ផសស | 67.5% | 76.1% | 85.7% |
| កំណើនឥណទាន | % | 13.4% | 22.4% | 25.7% |
| **ពាណិជ្ជកម្មអន្តរជាតិ** | | | | |
| ទំហំពាណិជ្ជកម្មនាំចេញ | ប៊ីលានរៀល | 10,165 | 11,419 | 12,937 |
| ទំហំពាណិជ្ជកម្មនាំចូល | ប៊ីលានរៀល | 12,763 | 15,852 | 18,381 |
| **វិនិយោគឯកជន** | | | | |
| គម្រោង | ចំនួន | 21 | 36 | 63 |
| ទុនវិនិយោគ | លានដុល្លារ | 131 | 469 | 1,936 |
| បង្កើតការងារ | ពាន់នាក់ | 33,825 | 38,029 | 92,245 |
| **ទេសចរណ៍** | | | | |
| អ្នកធ្វើដំណើរឆ្លងកាត់ប្រទេសកម្ពុជា | នាក់ | 1,502,896 | 1,711,253 | 1,877,853 |
| **វិស័យសំណង់** | | | | |
| គម្រោង | ចំនួន | 786 | 879 | 989 |
| ក្រឡាផ្ទៃ | ម២ | 2,073,040 | 1,187,931 | 3,753,631 |
| តម្លៃសាងសង់ | លានដុល្លារ | 1,282 | 506 | 1,678 |
| **ថ្លៃទំនិញលើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក)** [8] | | | | |
| អង្ករ | ដុល្លារ/ តោន | 340 | 379 | 401 |
| ប្រេងឆៅ (Brent) -- បារ៉ែល | ដុល្លារ/ បារ៉ែល | 46 | 63 | 65 |
| កៅស៊ូ | ដុល្លារ/ តោន | 1,871 | 1,569 | 1,353 |

ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ, និងធនាគារជាតិ

[8] គឺជាថ្លៃទំនិញចុងត្រីមាស

*រូបភាព 1 ÷ ស្ថានភាពសូចនាករសេដ្ឋកិច្ចសំខាន់ៗ*




ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ, និងធនាគារជាតិ

# ២. សូចនាករតាមវិស័យ

## ២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

*តារាង 2 ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (មធ្យមប្រចាំត្រីមាសទី៤) -- ឆ្នាំ២០១៨*

| សូចនាករ | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| **មុខទំនិញគ្រប់មុខ** | 166.2 | 170.5 | 174.9 |
| អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | 201.9 | 207.4 | 212.9 |
| ភេសជ្ជៈមានជាតិស្រវឹង និង ថ្នាំជក់ | 157.6 | 159.8 | 165.3 |
| សម្លៀកបំពាក់ និង ស្បែកជើង | 141.5 | 145.0 | 148.9 |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 124.6 | 124.7 | 126.4 |
| គ្រឿងសង្ហារឹម សម្ភារប្រើប្រាស់ និងការថែទាំ | 148.9 | 150.2 | 151.3 |
| សុខាភិបាល | 131.9 | 133.6 | 136.1 |
| ការដឹកជញ្ជូន | 109.4 | 113.8 | 115.4 |
| គមនាគមន៍ | 68.3 | 67.9 | 67.5 |
| ការកំសាន្ត និងវប្បធម៌ | 118.1 | 118.4 | 118.7 |
| ការសិក្សា | 160.1 | 159.6 | 159.7 |
| ភោជនីយដ្ឋាន | 241.2 | 257.6 | 274.5 |
| ទំនិញ និង សេវាកម្មផ្សេងៗ | 139.8 | 141.6 | 145.2 |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

*រូបភាព 2 ៖ ស្ថានភាពអតិផរណា (មធ្យមប្រចាំត្រីមាស)*




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

## ២.៣. អត្រាប្តូរប្រាក់

*តារាង 3 ៖ អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស) -- ឆ្នាំ២០១៩*

| អត្រាប្តូរប្រាក់ចុងខែ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| 2011 | 4,043 | 4,045 | 4,095 | 4,065 |
| 2012 | 4,030 | 4,038 | 4,056 | 4,007 |
| 2013 | 3,995 | 4,032 | 4,062 | 4,020 |
| 2014 | 3,994 | 4,026 | 4,060 | 4,070 |
| 2015 | 4,043 | 4,056 | 4,092 | 4,051 |
| 2016 | 4,023 | 4,055 | 4,094 | 4,042 |
| 2017 | 4,016 | 4,047 | 4,080 | 4,037 |
| 2018 | 4,012 | 4,046 | 4,073 | 4,047 |
| 2019 | 4,006 | | | |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

*រូបភាព 3 ÷ ស្ថានភាពអតិផរណា និងអត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស) -- ឆ្នាំ២០១៩*




ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៤. ហិរញ្ញវត្ថុសាធារណៈ

*តារាង 4 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកចំណូល*

| ប៊ីលានរៀល | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| I. ចំណូលក្នុងប្រទេស | 4,310 | 4,358 | 4,927 |
| ១. ចំណូលចរន្ត | 4,292 | 4,345 | 4,896 |
| *ក. ចំណូលសារពើពន្ធ* | 3,915 | 3,985 | 4,352 |
| ១. ពន្ធផ្ទាល់ | 1,279 | 979 | 975 |
| ពន្ធលើប្រាក់បៀវត្ស | 252 | 188 | 178 |
| ពន្ធលើប្រាក់ចំណេញ | 951 | 791 | 797 |
| ពន្ធលើផលទុនដីធ្លី និងផ្ទះសំបែង | 76 | 0 | 0 |
| ២. ពន្ធប្រយោល | 2,180 | 2,491 | 2,791 |
| ពន្ធលើផលរបរ | 0 | 0 | 0 |
| អាករលើតម្លៃបន្ថែម | 1,268 | 1,243 | 1,478 |
| អាករពិសេស | 888 | 1,223 | 1,292 |
| ចំណូលពន្ធផ្សេងៗទៀត | 24 | 25 | 22 |
| ៣. ពន្ធពាណិជ្ជកម្មក្រៅប្រទេស | 456 | 515 | 586 |
| ពន្ធនាំចូល | 448 | 500 | 575 |
| ពន្ធនាំចេញ | 9 | 14 | 11 |
| ពន្ធនាំចេញផ្សេងៗទៀត | 0 | 0 | 0 |

| ប៊ីលានរៀល | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| *ខ. ចំណូលមិនមែនសារពើពន្ធ* | 377 | 360 | 544 |
| ចំណូលពីនេសាទ | 1 | 0 | 1 |
| ចំណូលពីព្រៃឈើ | 0 | 0 | 0 |
| ចំណូលពីការជួលសហគ្រាស | 0 | 0 | 166 |
| ចំណូលពីអាកាសចរស៊ីវិល | 23 | 25 | 7 |
| ចំណូលពីសម្បទាន | 80 | 100 | 88 |
| ចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 2 | 10 | 12 |
| អាករស្មានទូត (ចំណូលពីលិខិតឆ្លងដែន និងទិដ្ឋាការ) | 136 | 0 | 0 |
| ផលពីការបង់សិទ្ធិប្រលង | 1 | 0 | 0 |
| ចំណូលពីការជួល | 2 | 0 | 0 |
| ចំណូលមិនមែនពន្ធផ្សេងៗ | 132 | 225 | 269 |
| **២. ចំណូលមូលធន** | 18 | 13 | 31 |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## *តារាង 5 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកចំណាយ*

| ប៊ីលានរៀល | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| **II. ចំណាយសរុប** | 3,402 | 3,583 | 3,714 |
| **១. ចំណាយចរន្ត** | 2,237 | 2,770 | 2,866 |
| ***ក. ការពារ និងសន្តិសុខជាតិ*** | 800 | 916 | 989 |
| ***ខ. រដ្ឋបាលស៊ីវិល*** | 1,319 | 1,703 | 1,715 |
| ***គ. ចំណាយការប្រាក់*** | 118 | 151 | 162 |
| **២. ចំណាយមូលធន** | 1,165 | 813 | 848 |
| ហិរញ្ញប្បទានក្នុងស្រុក | 184 | 242 | 182 |
| ពីចំណូលក្នុងស្រុក | 184 | 220 | 182 |
| ពីជំនួយជាទំនិញ | 0 | 22 | 0 |
| ហិរញ្ញប្បទានពីបរទេស | 981 | 571 | 666 |
| ***និនភាពចរន្ត (សាច់ប្រាក់)*** | 2,042 | 1,574 | 2,030 |
| ***និនភាពទូទៅ (សាច់ប្រាក់)*** | 895 | 774 | 1,213 |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## តារាង 6 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) -- ផ្នែកហិរញ្ញប្បទាន

| ប៊ីលានរៀល | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| III. ហិរញ្ញប្បទាន | (895) | (774) | (1,213) |
| ១. ហិរញ្ញប្បទានពីបរទេស | 887 | 403 | 466 |
| ទ្រទ្រង់ថវិកា | 0 | 22 | 0 |
| ជំនួយគម្រោងអភិវឌ្ឍន៍ | 987 | 557 | 697 |
| រំលស់បំណុលបរទេស | (101) | (177) | (232) |
| ២. ហិរញ្ញប្បទានក្នុងស្រុក | (2,570) | 102 | (25) |
| បញ្ញើរដ្ឋាភិបាល | (1,820) | (850) | (1,818) |
| វិស័យឯកជន | (493) | 0 | 0 |
| ផ្សេងៗ | (257) | 952 | 1,793 |
| ៣. ប្រតិបត្តិការកំពុងដំណើរការ | 789 | (1,279) | (1,654) |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រូបភាព 4 ÷ ស្ថានភាពតុល្យភាពថវិកាចរន្ត (គិតជាប៊ីលានរៀល)




ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៥. ឥណទាន និងរូបិយវត្ថុ

*តារាង 7÷ ស្ថានភាពរូបិយវត្ថុ*

| (ប៊ីលានរៀល) | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | 36,490 | 46,707 | 58,144 |
| ទ្រព្យសកម្មបរទេស | 51,537 | 64,171 | 76,503 |
| ទ្រព្យអកម្មបរទេស | (15,047) | (17,464) | (18,359) |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | 24,057 | 28,457 | 34,872 |
| ឥណទានក្នុងស្រុក | 47,567 | 56,306 | 69,194 |
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | (9,819) | (12,381) | (17,381) |
| ផ្នែកមិនមែនរដ្ឋាភិបាល | 57,386 | 68,687 | 86,575 |
| **ទ្រព្យសកម្មផ្នែកផ្សេងៗ** | (23,510) | (27,849) | (34,322) |
| ប្រាក់បញ្ញើហាមឃាត់ | (1,358) | (1,675) | (2,068) |
| មូលធន និង ទុនបំរុង | (19,361) | (23,861) | (28,299) |
| ផ្សេងៗ | (2,792) | (2,313) | (3,955) |
| **រូបិយវត្ថុទូទៅ (M2)** | 60,547 | 75,164 | 93,016 |
| រូបិយវត្ថុ (M1) | 7,525 | 9,578 | 11,658 |
| *រូបិយវត្ថុក្រៅធនាគារ* | 6,835 | 8,466 | 10,540 |
| *ប្រាក់បញ្ញើចរន្ត* | 690 | 1,113 | 1,118 |
| រូបិយវត្ថុផ្សេងៗ | 53,023 | 65,586 | 81,358 |
| *ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ* | 1,843 | 2,106 | 2,660 |
| *ប្រាក់បញ្ញើជារូបិយប័ណ្ណ (បរទេស)* | 51,179 | 63,479 | 78,697 |

ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៦. វិស័យពាណិជ្ជកម្ម

*រូបភាព 5÷ បរិក្ខារសំណង់ ទោចក្រ-យានយន្ត និងវាយនភ័ណ្ឌនិងសម្លៀកបំពាក់ (គិតជាប៊ីលានរៀល)*




ប្រភពៈ ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*តារាង 8÷ ការនាំចូលតាមមុខទំនិញសំខាន់ៗ (គិតជាប៊ីលានរៀល)*

| មុខទំនិញ | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| ថ្នាំពេទ្យ | 143 | 184 | 206 |
| ភេសជ្ជៈ គ្រឿងស្រវឹង និងបារី | 439 | 694 | 603 |
| ស្ករស និងប៊ីចេង | 59 | 49 | 41 |
| ប្រេងឆា និងអាហារផ្សេងៗ | 287 | 384 | 513 |
| សម្ភារសំណង់ | 617 | 807 | 1,218 |
| អេឡិចត្រូនិច | 6 | 94 | 132 |
| វាយនភ័ណ្ឌ | 3,368 | 4,280 | 4,402 |
| ទោចក្រ-យានយន្ត | 1,129 | 1,312 | 1,856 |
| គ្រឿងបន្លាស់យានយន្ត | 14 | 21 | 28 |
| បរិក្ខារត្រជាក់ | 54 | 58 | 68 |
| មាស | 315 | 241 | 130 |
| ប្រេងឥន្ធនៈ | 1,011 | 878 | 1,696 |
| ជីកសិកម្ម | 186 | 153 | 108 |
| ផ្សេងៗ | 5,133 | 6,036 | 7,380 |
| **សរុប** | 12,763 | 15,852 | 18,381 |

ប្រភពៈ ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រូបភាព 6 ÷ ស្ថានភាពមុខទំនិញនាំចេញសំខាន់ៗ (គិតជាប៊ីលានរៀល)




ប្រភព៖ ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រូបភាព 7 ÷ ស្ថានភាពនាំចេញទៅទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)




ប្រភព៖ ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## *តារាង ១÷ មុខទំនិញនាំចេញ (គិតជាប៊ីលានរៀល)*

| មុខទំនិញ | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| សម្លៀកបំពាក់ | 6,445 | 7,098 | 7,599 |
| ស្បែកជើង | 841 | 905 | 1,111 |
| វាយនភ័ណ្ឌផ្សេងៗ | 168 | 390 | 1,158 |
| គ្រឿងបង្គុំអេឡិចត្រូនិច | 510 | 174 | 140 |
| គ្រឿងបង្គុំរថយន្ត | 7 | 48 | 82 |
| កង់ | 411 | 431 | 435 |
| ឈើមូល | 0 | 67 | 86 |
| ឈើកែច្នៃ | 0 | 1 | 0 |
| ក្តារបន្ទះ | 0 | 11 | 20 |
| ផលិតផលផ្សេងៗពីឈើ | 50 | 41 | 8 |
| អង្ករ | 334 | 428 | 490 |
| ស្រូវ | 1 | 0 | 0 |
| កៅស៊ូ | 266 | 210 | 176 |
| ស្ករស | 34 | 81 | 43 |
| ផលិតផលជលផល | 1 | 4 | 0 |
| ផលិតផលកសិកម្មផ្សេងៗ | 160 | 111 | 88 |
| បារី | 22 | 14 | 15 |
| ខ្សែភ្លើង និងបង្គុំខ្សែភ្លើង | 0 | 132 | 148 |
| សំបកកំប៉ុង និងគម្របកំប៉ុង | 0 | 14 | 1 |
| មាស | 0 | 0 | 0 |
| ផលិតផលផ្សេងៗ | 915 | 1,260 | 1,336 |
| **នាំចេញសរុប** | 10,165 | 11,419 | 12,937 |

ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៧. ការវិនិយោគឯកជន

*តារាង 10 ÷ ស្ថិតិវិនិយោគវិស័យឯកជនក្រៅតំបន់សេដ្ឋកិច្ចពិសេស (អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)*

| ការអនុញ្ញាតវិនិយោគដោយ (CDC) | ឯកតា | ត្រីមាសទី១ | | |
|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ |
| គម្រោង | ចំនួន | 21 | 36 | 63 |
| បង្កើតការងារ | ការងារ | 33,825 | 38,029 | 92,245 |
| ទុនវិនិយោគលើវិស័យ | | | | |
| កសិកម្ម | លានដុល្លារ | 8 | 210 | 0 |
| ឧស្សាហកម្ម | លានដុល្លារ | 116 | 154 | 310 |
| សេវាកម្ម | លានដុល្លារ | 4 | 29 | 7 |
| ទេសចរណ៍ | លានដុល្លារ | 4 | 75 | 1,619 |
| **សរុប** | **លានដុល្លារ** | 131 | 469 | 1,936 |
| ទុនវិនិយោគក្នុងស្រុក | លានដុល្លារ | 24 | 134 | 1,050 |
| ទុនវិនិយោគបរទេស | លានដុល្លារ | 107 | 335 | 885 |

ប្រភពៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

*រូបភាព 8 ÷ ចំនួនគម្រោង និងទុនវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស (គិតជាលានដុល្លារអាមេរិក)*




ប្រភពៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ២.៨. វិស័យទេសចរណ៍

*តារាង 11 ÷ ចំនួនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា*

| សូចនាករ | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| សរុប | 1,502,896 | 1,711,253 | 1,877,853 |
| តាមផ្លូវអាកាស | 921,410 | 1,157,632 | 1,299,122 |
| ភ្នំពេញ | 346,603 | 495,215 | 581,709 |
| សៀមរាប | 552,477 | 631,444 | 583,879 |
| កងកេង | 22,330 | 30,973 | 133,534 |
| តាមផ្លូវគោក និង ផ្លូវទឹក | 581,486 | 553,621 | 578,731 |
| ផ្លូវគោក | 509,961 | 498,016 | 512,309 |
| ផ្លូវទឹក | 71,525 | 55,605 | 66,422 |

ប្រភព: ក្រសួងទេសចរណ៍

*រូបភាព 9 ÷ កំណើនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា (គិតជា %)*




ប្រភព: ក្រសួងទេសចរណ៍

## ២.៩. វិស័យសំណង់

*តារាង 12 ÷ គម្រោងអនុញ្ញាតសាងសង់*

| | ឯកត្តា | ត្រីមាសទី១ | | |
|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ |
| **សំណើសុំសាងសង់** | | | | |
| គម្រោង | ចំនួន | 786 | 879 | 989 |
| តម្លៃសាងសង់ | លានដុល្លារ | 1,282 | 506 | 1,678 |
| **សំណើសុំសាងសង់តាមប្រភេទ** | | | | |
| សំណង់សាធារណៈ | ម² | 6,993 | 10,324 | 41,016 |
| លំនៅដ្ឋាន និងភូមិគ្រឹះ | ម² | 1,391,185 | 627,311 | 2,505,888 |
| សំណង់ឧស្សាហកម្ម | ម² | 306,639 | 194,321 | 306,863 |
| សំណង់ពាណិជ្ជកម្ម | ម² | 152,205 | 298,955 | 780,899 |
| សំណង់ទេសចរណ៍ | ម² | 215,896 | 56,908 | 110,749 |
| សំណង់វិនិយោគផ្សេងៗ | ម² | 120 | 112 | 8,216 |
| **សរុប** | **ម²** | 2,073,039 | 1,187,931 | 3,753,631 |

ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

*រូបភាព 10 ÷ សំណើសុំសាងសង់ គិតជាក្រឡាផ្ទៃ ចែកតាមប្រភេទសំណង់*




ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

*តារាង 13 ÷ ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក)*

| មុខទំនិញ | ឯកតា | ទីផ្សារ | ត្រីមាសទី១ | | |
|---|---|---|---|---|---|
| | | | ២០១៧ | ២០១៨ | ២០១៩ |
| អង្ករ | តោន/ ដុល្លារ | បាងកក | 358 | 404 | 406 |
| ប្រេងឆៅ Brent | ធុង/ ដុល្លារ | ក្រុងឡុងដ៍ | 52 | 66 | 66 |
| កៅស៊ូ | តោន/ ដុល្លារ | សិង្ហបុរី | 2,350 | 1,758 | 1,723 |
| មាស | អោន/ ដុល្លារ | ហុងកុង | 1,351 | 1,453 | 1,427 |
| ពោតក្រហម | តោន/ ដុល្លារ | ស៊ីកាហ្គោ | 159 | 172 | 165 |
| សណ្តែកសៀង | តោន/ ដុល្លារ | ស៊ីកាហ្គោ | 405 | 433 | 370 |
| ប្រេងដូង | តោន/ ដុល្លារ | រ៉ុតធើដាំ | 1,547 | 1,123 | 679 |
| ស្ករស | តោន/ ដុល្លារ | ក្រុងឡុង | 349 | 403 | 369 |

ប្រភព: គេហទំព័រធនាគារពិភពលោក

*រូបភាព 11 ÷ ថ្លៃជីកសិកម្មលើទីផ្សារអន្តរជាតិសម្រាប់ត្រីមាសទី៤ (គិតជាដុល្លារអាមេរិក/ម៉ែត្រទ្រីកតោន)*




ប្រភព: គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*តារាង 14 ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ឆ្នាំគោល ២០១០=១០០)*

| មុខទំនិញ | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| ប្រេងឥន្ធនៈ | 51 | 64 | 64 |
| ផលិតផលកសិកម្ម | 89 | 91 | 83 |
| ម្ហូបអាហារ | 93 | 95 | 86 |
| ឈើ | 83 | 92 | 87 |
| ជីគីមី | 76 | 75 | 84 |

ប្រភពៈ គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

*តារាង 15 ÷ អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិធៀបនឹងដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*

| រូបិយប័ណ្ណ | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ |
| ជប៉ុន (យ៉េន) | 111.26 | 106.22 | 110.82 |
| ហុងកុង (ដុល្លារ) | 7.77 | 7.85 | 1.36 |
| សឹង្ហបុរី (ដុល្លារ) | 1.40 | 1.31 | 1.36 |
| ម៉ាឡេស៊ី (រីងហ្គីត) | 4.42 | 3.86 | 4.08 |
| ហ្វីលីពីន (ប៉េសូ) | 50.11 | 52.16 | 31.59 |
| ថៃ (បាត) | 34.39 | 31.13 | 31.59 |
| ឥណ្ឌូនេស៊ី (រូព្យា) | 13,315.60 | 13,732.50 | 1,136.46 |
| កូរ៉េ (វ៉ុន) | 1,114.45 | 1,061.17 | 1,136.46 |
| តៃវ៉ាន់ (ដុល្លារ) | 30.28 | 29.08 | 30.85 |
| ចិន (រ៉េនមីនប៊ី) | 6.89 | 6.28 | 6.71 |
| ឡាវ (គីប) | 3,947.01 | 3,973.61 | 3,987.50 |
| វៀតណាម (ដុង) | 8,081.81 | 8,236.54 | 8,590.00 |
| ឥណ្ឌា (រូពី) | 22,501.10 | 22,741.30 | 23,196.50 |
| រុស្ស៊ី (រូប) | 64.75 | 64.92 | 69.32 |
| អូស្ត្រាលី (ដុល្លារ) | 56.35 | 57.23 | 65.64 |
| អង់គ្លេស (ផោន) | 1.30 | 1.30 | 1.41 |
| អឺរ៉ុប (អឺរ៉ូ) | 0.80 | 0.71 | 0.77 |

ប្រភពៈ OANDA (Internet)

# ឧបសម្ព័ន្ធ

*តារាង 16 ÷ ស្ថិតិកសិកម្ម*

| ផលិតកម្មកសិកម្ម និងនាំចេញ | ឯកតា | ត្រីមាសទី១ | | |
|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ |
| **ផ្ទៃដីដាំដុះ** | | | | |
| ស្រូវ | ហិកតា | 3,118,160 | 3,206,523 | 3,332,323 |
| ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម | ហិកតា | 1,030,596 | 1,085,404 | 1,066,940 |
| កៅស៊ូ | ហិកតា | 435,991 | 436,812 | 436,356 |
| **ផ្ទៃដីប្រមូលផល** | | | | |
| ស្រូវ | ហិកតា | 3,097,253 | 2,808,782 | 2,899,199 |
| កៅស៊ូ | ហិកតា | 129,666 | 171,063 | 201,520 |
| **បរិមាណផល** | | | | |
| ស្រូវ | តោន | 9,926,816 | 9,087,548 | 9,585,354 |
| កៅស៊ូ (ក្រែប) | តោន | 36,788 | 37,025 | 48,779 |
| ជលផល | តោន | 149,698 | 150,538 | 160,842 |
| **នាំចេញ** | | | | |
| អង្ករ (*) | តោន | 157,620 | 155,298 | 157,038 |
| កៅស៊ូ | តោន | 34,130 | 35,698 | 33,977 |
| ស្ករ | តោន | 14,600 | 93,969 | 73,018 |
| ផលិតផលជលផល | តោន | 60 | 1,587 | 116 |
| ផលិតផលកសិកម្មផ្សេងៗ | តោន | 113,063 | 78,657 | 48,069 |

ប្រភព: របាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
របាយការណ៍ពាណិជ្ជកម្មប្រចាំខែ

*សម្គាល់÷ (*) ស្ថិតិនាំចេញពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។ ប៉ុន្តែស្ថិតិនៃការនាំចេញអង្ករពីកម្ពុជាទៅទីផ្សារអន្តរជាតិ កត់ត្រាតាមរយៈលេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ គិតត្រឹមត្រីមាសទី១ ឆ្នាំ២០១៩ មានរហូតដល់ ១៧០ ៨២១ តោន*

*រៀបចំដោយនាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច នៃអគ្គនាយកដ្ឋានគោលនយោបាយ*

*ទំនាក់ទំនង: (855) 12 997 616*

*(855) 89 898 878*

*Email: sead@mef.gov.kh*